**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## ការបង្ការបញ្ហាសុខភាពបណ្ដាលមកពីការពុលដោយបរិភោគត្រីក្រពត

ក្រសួងសុខាភិបាល សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋឱ្យបានជ្រាបថា នៅខេត្តកំពង់ឆ្នាំងមានករណីពុលចំនួន៧នាក់ បន្ទាប់ពីបរិភោគត្រីក្រពត ដោយមានអាការៈធ្ងន់ធ្ងរ ដែលទាមទារឱ្យមានការជួយសង្គ្រោះបន្ទាន់ពីមន្ទីរពេទ្យ។ ដោយមានការយកចិត្តទុកដាក់ព្យាបាលពីសំណាក់ក្រុមគ្រូពេទ្យ បច្ចុប្បន្នអ្នកជំងឺមានសភាពធូរស្រាលច្រើនហើយ។

ជាមួយគ្នានេះ **ក្រសួងសុខាភិបាលសូមក្រើនរំលឹក ដើម្បីចៀសវាងបាននូវការពុលត្រីក្រពត បង្កជាបញ្ហាសុខភាពដែលអាចធ្វើឱ្យបាត់បង់ជីវិត សូមបងប្អូនប្រជាពលរដ្ឋ កុំបរិភោគត្រីក្រពតដែលមានជាតិពុល ពីព្រោះជាតិពុលនៅក្នុងខ្លួនត្រី អាចបណ្ដាលឱ្យមានជំងឺធ្ងន់ធ្ងរ ឬស្លាប់។ ជាតិពុលនៅក្នុងខ្លួនត្រីក្រពតមិនអាចកំចាត់ចោលបានទេ ទោះបីជាបានចំអិន ឬដាក់ឱ្យកកក៏ដោយ។**

នៅក្នុងប្រទេសកម្ពុជា មាន**ត្រីក្រពត**ចំនួន ៩ប្រភេទ ក្នុងនោះមាន **៥ប្រភេទ មានជាតិពុល**។ តាមការស្រាវជ្រាវបានរកឃើញថា ត្រីក្រពតដែលមានជាតិពុល (មានភិនភាគដូចក្នុងរូបភាពភ្ជាប់ជូនខាងក្រោម) រួមមាន៖ **១. ត្រីក្រពតភ្នែកក្រហម** (Carinotetraodon Lorteti ឬ Redeye Puffer) មានទំហំអតិបរមា ៦ស.ម **២. ត្រីក្រពតអុចធំ** (Tetraodon Biocellatus ឬ Eyespot Pufferfish) មានទំហំអតិបរមា ៨ស.ម **៣. ត្រីក្រពតកូសាំងស៊ីន** (Monotrete Cochinchinensis) មានទំហំអតិបរមា ១៣,៥ស.ម **៤. ត្រីក្រពតអុចបៃតង** (Tetraodon Nigroviridis ឬ Spotted Green Pufferfish) មានទំហំអតិបរមា ១៧ស.ម. និង**៥. ត្រីក្រពតហ្លូវៀធីលីស** (Tetraodon Fluviatilis) មានទំហំអតិបរមា ១៧ស.ម។ **ត្រីក្រពតទាំងនេះ មានជាតិពុលខ្ពស់ និងអាចបណ្ដាលឱ្យមានជំងឺធ្ងន់ធ្ងរ និងស្លាប់បាន។** នៅពេលយើងបរិភោគត្រីទាំងនេះ ជាតិពុលបានជ្រាបទៅប៉ះពាល់ប្រព័ន្ធសរសៃប្រសាទកណ្ដាល និងអាចបណ្ដាលឱ្យស្លាប់។ ម្យ៉ាងទៀត ត្រីក្រពតទាំង ៥ប្រភេទខាងលើនេះ មានជាតិពុលខ្ពស់បំផុតនៅរដូវពងកូនបន្តពូជ ដែលជាធម្មតាកើតឡើងនៅក្នុងខែកុម្ភៈ មីនា និងចន្លោះខែកក្កដា ទៅខែកញ្ញា។ ចំពោះជាតិពុលនៅក្នុងខ្លួនត្រី ក៏មានកម្រិតខុសគ្នាដែរ គឺពងនិងស្លែមរបស់វាមានជាតិពុលខ្ពស់ជាងគេ បន្ទាប់មក គឺថ្លើម ពោះវៀន ស្បែក និងសាច់។

រោគសញ្ញា កើតក្រោយពីបរិភោគត្រីបែបនេះរយៈពេល ២០នាទីទៅ២ម៉ោង មានដូចជា រមាស់ចាក់ៗនៅបបូរមាត់ និងមាត់ បន្ទាប់មកមានអាការៈឈឺក្បាល វិលមុខ រមាស់ចាក់ៗនៅក្នុងអវៈយវៈ មានការពិបាកនិយាយ បាត់លំនឹងដងខ្លួន ខ្សោយសាច់ដុំ ខ្ជិន ស្ពឹកចុងដៃចុងជើង ក្អួត រាក ល្អិតល្ហៃ រឹងថ្គាម ឬអាចបណ្ដាលឱ្យស្លាប់។ នៅក្នុងករណីដែលពុលខ្លាំង ការស្លាប់អាចបណ្ដាលមកពីវិបត្តិផ្លូវដង្ហើម។ **វិធីសង្គ្រោះភ្លាមៗក្រោយពីពុល អាចធ្វើបានតាមរយៈធ្វើឱ្យក្អួត (ប្រសិនបើអាចធ្វើទៅបាន) ដែលអាចជួយបញ្ចេញជាតិពុលពីក្នុងខ្លួនបានមួយចំណែក ហើយអ្នកពុលនោះត្រូវប្រញាប់ស្វែងរក ការជួយសង្គ្រោះបន្ទាន់នៅតាមមូលដ្ឋានសុខាភិបាលដែលនៅជិតលោកអ្នកបំផុត ដោយស្ថានភាពអ្នកពុលតម្រូវឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានពីគ្រូពេទ្យជាចាំបាច់។**

ថ្ងៃសៅរ៍ ១កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤

ក្រសួងសុខាភិបាល

# លក្ខណៈសម្គាល់ត្រីក្រពត ៥ប្រភេទ មានជាតិពុល

លក្ខណៈសម្គាល់ត្រីក្រពត កូសាំងស៊ីន (*Pao cochinchinensis*) មានសារធាតុពុល




លក្ខណៈសម្គាល់ត្រីក្រពត ភ្នែកក្រហម (*Carinotetraodon lorteti*) មានសារធាតុពុល




លក្ខណៈសម្គាល់ត្រីក្រពត អុចបៃតង (*Dichotomyctere nigroviridis*) មានសារធាតុពុល




លក្ខណៈសម្គាល់ត្រីក្រពត អុចធំ (*Dichotomyctere ocellatus*) មានសារធាតុពុល




លក្ខណៈសម្គាល់ត្រីក្រពត ខ្មៅ (*Dichotomyctere fluviatilis*) មានសារធាតុពុល



# រូបភាពត្រីក្រពត ៥ប្រភេទ មានជាតិពុល





ត្រីក្រពតភ្នែកក្រហម ( Max. 6 cm ) ( Carinotetraodon lorteti ឬ Redeye puffer )



ត្រីក្រពតអុចធំ ( Max. 8 cm ) Tetraodon biocellatus ឬ Eyespot pufferfish



ត្រីក្រពតកូសាំងស៊ីន ( Max. 13.5 cm ) Monotrete cochinchinensis



ត្រីក្រពតអុចបៃតង ( Max. 17 cm ) ( Tetraodon nigroviridisឬ Spotted green pufferfish )



ត្រីក្រពត ( Max. 17 cm ) Tetraodon fluviatilis

# រូបភាពត្រីក្រពត ៩ប្រភេទ នៅប្រទេសកម្ពុជា

**អម្បូរ TETRAODONTIDAE**



ត្រីក្រពតបៃតង (Max. 13 cm)
*Auriglobus nefastus*
Greenbottle pufferfish




ត្រីក្រពតភ្នែកក្រហម (Max. 6 cm)
*Carinotetraodon lorteti*
Redeye puffer (ប្រភេទត្រីក្រពតពុល)




ត្រីក្រពតខ្មែរ (Max. 7 cm)
*Monotrete cambodgiensis*
Tetraodontidae




ត្រីក្រពតកូសាំងស៊ីន (Max. 13.5 cm)
*Monotrete cochinchinensis*
(ប្រភេទត្រីក្រពតពុល)



ត្រីក្រពតលឿង (Max. 15 cm)
*Tetraodon abei*



ត្រីក្រពតបន្លា (Max. 12 cm)
*Tetraodon baileyi*



ត្រីក្រពតអុចធំ (Max. 8 cm)
*Tetraodon biocellatus*
Eyespot pufferfish(ប្រភេទត្រីក្រពតពុល)



ត្រីក្រពត (Max. 17 cm)
*Tetraodon fluviatilis*(ប្រភេទត្រីក្រពតពុល)



ត្រីក្រពតអុចបៃតង (Max. 17 cm)
*Tetraodon nigroviridis*
Spotted green pufferfish(ប្រភេទត្រីក្រពតពុល)

ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩